# សហគមន៍ខ្មែរកម្ពុជាក្រោម

**KHMER KAMPUCHEA KROM COMMUNITY**

**LA COMMUNAUTÉ DU KHMER KAMPUCHEA KROM**

លេខ០៣៧ស៊ី/០៨ ស.ខ.ក.ក.

## ក្រាបបង្គំទូលថ្វាយ

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា**

**ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត !**

ទូលព្រះបង្គំជាខ្ញុំ **ថាច់ សេដ្ឋា** អតីតសមាជិកព្រឹទ្ធសភា នាយកប្រតិបត្តិសហគមន៍ខ្មែរ កម្ពុជាក្រោម សូមក្រាបថ្វាយបង្គំព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ជាទីសក្ការដ៏ខ្ពង់ខ្ពស់!

នៅក្នុងព្រះរាជដំណើរយាងបំពេញព្រះរាជទស្សនកិច្ចនៅសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តែកនេះ ទូលព្រះបង្គំជាខ្ញុំ ក្នុងនាមតំណាងសហគមន៍ខ្មែរកម្ពុជាក្រោមទាំងមូល ដែលជ្រកក្រោម ម្លប់ព្រះបារមីនៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង សូមព្រះបរមរាជានុញ្ញាតក្រាបបង្គំទូលថ្វាយ នូវ សំណូមពរដ៏សំខាន់និងចាំបាច់មួយចំនួន ដើម្បីព្រះករុណាជាអម្ចាស់ជីវិតលើត្បូង លើកជូនប្រមុខ ថ្នាក់ដឹកនាំបក្ស រដ្ឋ រដ្ឋសភានៃសាធារណរដ្ឋសង្គមនិយមវៀតណាមក្នុងពេលជួបព្រះសវនាការ ។

សំណូមពរទាំងនោះរួមមាន :

១_សូមអាជ្ញាធរវៀតណាមដោះលែងព្រះសង្ឃ៥ព្រះអង្គ ដែលបានចាប់ផ្សឹក និងកាត់ទោស ដាក់ពន្ធនាគារពី២ឆ្នាំ ទៅ៤ឆ្នាំ កាលពីថ្ងៃទី១០ ខែឧសភាឆ្នាំ២០០៧ ដោយសារតែការតវ៉ាក្នុងការ សិក្សារៀនសូត្រអក្សរសាស្ត្រខ្មែរ និងប្រឆាំងនិងបំរាមមិនឲ្យព្រះសង្ឃចេញទ្រង់បិណ្ឌបាត្រ ។

ព្រះសង្ឃទាំង៥អង្គនោះមាន : ១-ព្រះភិក្ខុតឹម មឿន ជាប់ពន្ធនាគារ៤ឆ្នាំ។ ២-ព្រះភិក្ខុ យាញ ត្លូ ជាប់ពន្ធនាគារ៤ឆ្នាំ។ ៣-ព្រះភិក្ខុលី ធឿន ជាប់ពន្ធនាគារ២ឆ្នាំ។៤-ព្រះភិក្ខុថាច់ ធឿង ជាប់ពន្ធនាគារ២ឆ្នាំ។ ៥-ព្រះភិក្ខុលី ភ៉ង ជាប់ពន្ធនាគារ២ឆ្នាំ។

២_សូមអាជ្ញាធរវៀតណាមដោះលែងព្រះតេជគុណទឹម សាខន ព្រះចៅអធិការវត្តភ្នំដឹនខាង ជើង ឃុំ ភ្នំដឹន ស្រុកគីរីវង្ស ខេត្ត តាកែវ ដែលត្រូវសម្តេចសង្ឃរាជទេព វង្ស ចាប់ផ្សឹកដោយ រំលោភព្រះវិន័យសង្ឃទាំងកំរោល រួចបញ្ជូនទៅកាត់ទោសនៅប្រទេសវៀតណាមទាំងរំលោភរដ្ឋធម្ម នុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ ព្រះតេជគុណទឹម សាខនត្រូវតុលាការវៀតណាមកាត់ទោសឲ្យជាប់ ពន្ធនាគារចំនួន១ឆ្នាំ ប៉ុន្តែឮរចំនួន៥ឆ្នាំ។ បើគិតពីថ្ងៃចាប់ខ្លួនរហូតបច្ចុប្បន្ន ព្រះអង្គបានស្ថិតនៅក្នុង

ភូមិគ្រឹះលេខ២៤៦ , ផ្លូវ៣៧១ , ភូមិត្រពាំងឈូក , សង្កាត់ទឹកថ្លា , ខណ្ឌឫស្សីកែវ , រាជធានីភ្នំពេញ
ទូរស័ព្ទ-ទូរសារលេខ : (៨៥៥) ២៣ ៩៥៥ ៥៨១, ១២ ៨៥១ ៩៩១ / ៩០ ៨៨ ៨២.
អ៊ីមែល: kkcommunity@camintel.com or k.k.k.c@camitel.com; website: http://khmerkromngo.org

ពន្ធនាគារជិតមួយឆ្នាំហើយ(៣០_៦_២០០៧) ។

៣_អនុញ្ញាតប្រជារាស្ត្រខ្មែរនៅប្រទេសវៀតណាម(កម្ពុជាក្រោម) គោរពទំនៀមទម្លាប់របស់ខ្លួនដោយសេរី។ ដូចជាបុណ្យកឋិនទាន តាមពុទ្ធានុញ្ញាតក្នុងមួយឆ្នាំពុទ្ធសាសនិកជនអាចធ្វើបានពេញមួយខែ តែនៅខេត្តឃ្លាំ ពលលាវ ទឹកខ្មៅអាជ្ញាធរវៀតណាមអនុញ្ញាតឲ្យធ្វើតែមួយថ្ងៃប៉ុណ្ណោះ។

៤_ដើម្បីបង្ហាញពីទំនាក់ទំនងជាមិត្តភាពកាន់តែល្អប្រសើររវាងកម្ពុជា_វៀតណាមថែមទៀតនោះ សូមភាគីវៀតណាមអនុញ្ញាតបើក វិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យរង នៅខេត្តឃ្លាំងឡើងវិញ ព្រោះវិជ្ជាស្ថាននេះ មានការចូលរួមចំណែកកសាងពីព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ នៅក្នុងទសវត្សឆ្នាំ៤០ផងដែរ ។

៥_ស្នើរដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលរៀបចំកម្មវិធីបំពេញរាជទស្សនកិច្ចថ្វាយព្រះករុណាជាអម្ចាស់ជីវិតលើត្បូងនេះ សូមមេត្តារៀបចំថ្វាយព្រះអង្គបានយាងទៅកាន់តំបន់ដែលមានប្រជារាស្ត្រខ្មែររស់នៅច្រើន ដើម្បីប្រជារាស្ត្រនិងព្រះសង្ឃខ្មែរទាំងនោះ បានក្រាបបង្គំគាល់ព្រះអង្គដោយផ្ទាល់ ។

បពិត្រព្រះករុណាជាអម្ចាស់ជីវិតតំកល់លើត្បូង ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត!

ទូលព្រះបង្គំជាខ្ញុំ មិនគួររបើរខានដល់ព្រះរាជដំណើរយាងបំពេញព្រះរាជទស្សនកិច្ចរបស់ព្រះអង្គនេះទេ តែដោយទូលព្រះបង្គំជាខ្ញុំ យល់ឃើញថា ជាការសំខាន់ ហើយចាំបាច់បំផុតត្រូវតែទូលថ្វាយព្រះករុណាទ្រង់ជ្រាប ។ ដូច្នេះ សូមព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះមេត្តាប្រទានអភ័យដល់ទូលព្រះបង្គំជាខ្ញុំ ដោយព្រះរាជទានប្រោស ។

សូមថ្វាយព្រះពរព្រះករុណាជាអម្ចាស់ជីវិតលើត្បូង បានសម្រេចជោគជ័យដ៏ធំធេង នៅក្នុងព្រះរាជដំណើរយាងបំពេញទស្សនកិច្ចទៅកាន់ប្រទេសវៀតណាមលើកនេះ។

សូមព្រះករុណាជាអម្ចាស់ជីវិលើត្បូង ព្រះមេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់បំផុតអំពីទូលព្រះបង្គំជាខ្ញុំ។

សេចក្តីពុំគួរ សូមព្រះរាជទានប្រោស ។

ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៨

នាយកប្រតិបត្តិសហគមន៍ខ្មែរកម្ពុជាក្រោម

ថាច់ សេដ្ឋា

អតីតសមាជិកព្រឹទ្ធសភា

5 issues KKC requests Cambodian King Norodom Sihamoni to raise with host Vietnamese leaders:

1-Release 5 imprisoned Buddhist clergies.
2-Release abbot Indapanna Tim Sakhorn.
3-Allow Khmers in Vietnam (Kampuchea Krom) to practice their culture freely.
4-Re-open the Buddhist Institute in Khleang province that former King Norodom Sihanouk helps established in the 1940s.
5-Allow His Majesty the King to visit the regions, where Khmers reside in person.